នស/រកម/១០០៥/០២៥

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ភូតោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃអនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទោសទៅលើឧក្រិដ្ឋកម្មទាំងឡាយប្រឆាំងនឹងបុគ្គលដែលត្រូវការពារជាអន្តរជាតិ រួមទាំងភ្នាក់ងារការទូត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុងកាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

Com2 KKAM Kmer

# ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាស្ដីពី ការទប់ស្កាត់ និងការដាក់ទោសទៅលើឧក្រិដ្ឋកម្មទាំងឡាយប្រឆាំងនឹង បុគ្គលដែលត្រូវការពារជាអន្តរជាតិរួមទាំងភ្នាក់ងារការទូត

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាស្ដីពីការទប់ស្កាត់និងការដាក់ទោសទៅលើឧក្រិដ្ឋកម្មទាំងឡាយប្រឆាំងនឹងបុគ្គលដែលត្រូវការពារជាអន្តរជាតិរួមទាំងភ្នាក់ងារការទូត ដែលអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក នាថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

**មាត្រា ៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៥

[illegible]

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ដលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

ពានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា ព្រះហស្ដលេខា**

**ស ខេង នរោត្ដម សិរីវុឌ្ឍ**

លេខ [illegible] ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

កិច្ចប្រជុំពេញអង្គលើកទី ២២០២
ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៣

ឧបសម្ព័ន្ធ

អនុសញ្ញាស្តីពីការទប់ស្កាត់និងដាក់ទោសទៅលើឧក្រិដ្ឋកម្មទាំងឡាយ
ប្រឆាំងនឹងបុគ្គលដែលត្រូវការពារជាអន្តរជាតិ រួមទាំងភ្នាក់ងារការទូត

បណ្តារដ្ឋជាភាគីនៃអនុសញ្ញានេះ

ដោយចងចាំពីគោលបំណងនិងគោលការណ៍ របស់ធម្មនុញ្ញអ.ស.ប ពាក់ព័ន្ធនឹងការថែរក្សាសន្តិភាព អន្តរជាតិ និងការជំរុញទំនាក់ទំនងជាមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងរដ្ឋនិរដ្ឋ

ដោយយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងភ្នាកក់ងារការទូត និងបុគ្គលផ្សេងទៀតដែលត្រូវការពារ ជាអន្តរជាតិ ការបំផ្លាញសុវត្ថិភាពរបស់បុគ្គលទាំងនេះ នាំអោយមានការគំរាមកំហែងធ្ងន់ធ្ងរ ដល់ការថែរក្សា ទំនាក់ទំនងអន្តរជាតិ ជាធម្មតា ដែលមានសារៈសំខាន់ក្នុងបណ្តារដ្ឋ

ដោយជឿជាក់ថា គណៈកម្មការទទួលបន្ទុករឿងឧក្រិដ្ឋកម្មទាំងនេះ គឺជាការផ្តល់នូវកង្វល់មួយយ៉ាង ខ្លាំងចំពោះសហគមន៍អន្តរជាតិ

ដោយជឿជាក់ថា មានតំរូវការជាបន្ទាន់ដើម្បីអនុម័តវិធានការមានប្រសិទ្ធភាពនិងសមស្រប សំរាប់ ទប់ស្កាត់ និងដាក់ទោសទៅលើឧក្រិដ្ឋកម្មទាំងនេះ

បានព្រមព្រៀងដូចខាងក្រោមៈ

មាត្រា ១

សំរាប់គោលបំណងនៃអនុសញ្ញានេះ :

១." បុគ្គលដែលត្រូវការពារជាអន្តរជាតិ " មានន័យថា :

(ក) ប្រមុខរដ្ឋ រួមទាំងសមាជិកណាមួយក៏ដោយនៃអង្គសហសេវិក ដែលបំពេញមុខងារជា ប្រមុខរដ្ឋ ស្របតាមរដ្ឋធម្មនុញ្ញ ប្រមុខរដ្ឋាភិបាល រដ្ឋមន្ត្រីការបរទេស រួមទាំងសមាជិកគ្រួសាររបស់គាត់ នៅពេលណាដែលគាត់ ធ្វើដំណើរទៅក្នុងរដ្ឋមួយទៀត។

(ខ) តំណាងណាម្នាក់ ឬ មន្ត្រីរបស់រដ្ឋម្នាក់ ឬ មន្ត្រីណាម្នាក់ ឬ ភ្នាក់ងារផ្សេងទៀត

នៃអង្គការអន្តរជាតិ រដ្ឋាភិបាល ដែលនៅពេល និងទីកន្លែងដែលទទួលរងនូវឧក្រិដ្ឋកម្មចំពោះរូបគាត់ និវេសនដ្ឋាន ទីលំនៅឯកជន ឬ មធ្យោបាយដឹកជញ្ជូនរបស់គាត់ តាមច្បាប់អន្តរជាតិ គាត់ត្រូវបានទទួលការការពារពិសេស អោយរួចផុតពីការវាយ ប្រហារមកលើរូបគាត់ សេរីភាព សេចក្តីថ្លៃថ្នូរ ក៏ដូចជាសមាជិកនៃក្រុមគ្រួសាររបស់គាត់។

(២) " ជនល្មើសដែលត្រូវចោទប្រកាន់ " មានន័យថាជាបុគ្គល ដែលគេមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីកំណត់ ការចោទប្រកាន់ទោសចំពោះរូបគាត់តាមចក្ខុវិស័យដំបូង (ព្រីមា ហ្វាស៊ី) ថាគាត់បានប្រព្រឹត្ត ឬចូលរួមក្នុងឧក្រិដ្ឋ កម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មទាំងឡាយ ដែលមានចែងក្នុងមាត្រាទី២។

មាត្រា ២

១. ការប្រព្រឹត្តដោយចេតនាចំពោះ :

(ក) ឃាតកម្ម ការចាប់ជំរិត ឬការវាយប្រហារផ្សេងទៀត ទៅលើបុគ្គល ឬសេរីភាពនៃបុគ្គលដែល ត្រូវការពារជាអន្តរជាតិ

(ខ) ការវាយប្រហារដោយហឹង្សាទៅលើនិវេសណដ្ឋានផ្លូវការ លំនៅដ្ឋានឯកជន ឬ មធ្យោបាយដឹក ជញ្ជូនរបស់បុគ្គលដែលត្រូវការពារជាអន្តរជាតិ ដែលទំនងជានឹងបង្កអោយមានគ្រោះថ្នាក់ដល់រូបគាត់ ឬសេរីភាព របស់គាត់

(គ) ការគំរាមកំហែងថានឹងធ្វើការវាយប្រហារបែបនេះ

(ឃ) ការប៉ុនប៉ងថានឹងធ្វើការវាយប្រហារបែបនេះ និង

(ង) អំពើមួយដែលបង្កើតបានជាការចូលរួមសំគំនិត ក្នុងការវាយប្រហារបែបនេះ រដ្ឋសមាជិក នីមួយៗ ត្រូវកំណត់ថាជាឧក្រិដ្ឋកម្ម ក្នុងច្បាប់របស់រដ្ឋនោះ។

(២) រដ្ឋសមាជិកនីមួយៗត្រូវកំណត់ថា ឧក្រិដ្ឋកម្មទាំងនេះត្រូវទទួលទោសសមស្រប ដោយគិតពីស្ថាន ទំងន់នៃឧក្រិដ្ឋកម្មទាំងនោះ។

(៣) វាក្យខ័ណ្ឌទី ១ និងទី ២ នៃមាត្រានេះ តាមច្បាប់អន្តរជាតិ មិនអាចដកកាតព្វកិច្ច របស់រដ្ឋសមាជិក អោយរួចផុតពីការចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់ការវាយប្រហារផ្សេងទៀត ទៅលើបុគ្គល សេរីភាព ឬ សេចក្តីថ្លៃថ្នូរ របស់បុគ្គលដែលត្រូវការពារជាអន្តរជាតិឡើយ។

មាត្រា ៣

១. រដ្ឋសមាជិកនីមួយៗត្រូវចាត់វិធានការចាំបាច់ដូចនេះ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួន លើឧក្រិដ្ឋកម្មទាំង ឡាយ ដូចមានចែងក្នុងមាត្រា ២ តាមករណីដូចខាងក្រោម:

(ក) នៅពេលដែលមានការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅក្នុងទឹកដីរបស់រដ្ឋនោះ ឬនៅលើនាវា ឬយន្តហោះ ដែលបានចុះបញ្ជីនៅក្នុងរដ្ឋនោះ

(ខ) នៅពេលដែលជនល្មើសត្រូវចោទប្រកាន់ មានសញ្ជាតិរបស់រដ្ឋនោះ

(គ) នៅពេលដែលមានការប្រព្រឹត្តបទល្មើស ប្រឆាំងនឹងបុគ្គលដែលត្រូវការពារជាអន្តរជាតិ ដូចមានកំណត់ក្នុងមាត្រា១ ដែលទទួលបាននូវលក្ខណៈនេះ ក្នុងមុខងារដែលគាត់បំពេញភារកិច្ចក្នុងនាមរដ្ឋនោះ។

២. ដូចគ្នានេះដែរ រដ្ឋសមាជិកនីមួយៗ ត្រូវចាត់វិធានការតាមការចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួន លើ ឧក្រិដ្ឋកម្មទាំងនេះ ក្នុងករណីដែលជនល្មើសត្រូវចោទប្រកាន់មានវត្តមាននៅក្នុងទឹកដីរបស់ខ្លួន ហើយខ្លួនមិនធ្វើ បត្យាប័នជននោះ តាមមាត្រាទី៨ ទៅអោយរដ្ឋណាមួយ ដែលមានចែងក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រានេះ។

៣. អនុសញ្ញានេះមិនបានដកចេញនូវយុត្តាធិការព្រហ្មទណ្ឌណាមួយ ដែលត្រូវអនុវត្តតាមច្បាប់ក្នុងស្រុកឡើយ។

មាត្រា ៤

បណ្តារដ្ឋភាគីទាំងឡាយ ត្រូវសហប្រតិបត្តិការក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មទាំងឡាយ ដូចមានចែងក្នុងមាត្រា ២ ជាពិសេសដោយ:

(ក) ចាត់រាល់វិធានការសមស្របទាំងឡាយ ដើម្បីទប់ស្កាត់រាល់ការរៀបចំក្នុងទឹកដីរបស់ខ្លួន ដើម្បីប្រព្រឹត្ត បទល្មើសទាំងនេះ នៅក្នុង ឬ នៅក្រៅទឹកដីរបស់ខ្លួន

(ខ) ផ្លាស់ប្តូរពត៌មាន និងសហការចាត់រាល់វិធានការរដ្ឋបាល និងវិធានការសមស្របផ្សេងទៀត ដើម្បីទប់ ស្កាត់នូវការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។

មាត្រា ៥

១. រដ្ឋសមាជិកដែលបទល្មើសណាមួយ ដូចមានចែងក្នុងមាត្រា២ បានកើតឡើង ប្រសិនបើខ្លួនយល់

ថា ជនល្មើសដែលត្រូវចោទប្រកាន់ បានគេចចេញពីទឹកដីរបស់ខ្លួនហើយ ត្រូវទំនាក់ទំនងជាមួយបណ្តារដ្ឋផ្សេងទៀត ដែលពាក់ព័ន្ធ តាមមធ្យោបាយដោយផ្ទាល់ ឬតាមរយៈលោកអគ្គលេខាធិការអ.ស.ស.ប ពីហេតុការណ៍នានា ដែល ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនេះ និងរាល់ពត៌មានទាំងឡាយដែលអាចរកបាន ពាក់ព័ន្ធនឹងអត្តសញ្ញាណជនល្មើស ដែលត្រូវចោទប្រកាន់ ។

២. នៅពេលណាដែលឧក្រិដ្ឋកម្មទាំងឡាយដូចមានចែងក្នុងមាត្រា២ ត្រូវបានប្រព្រឹត្តចំពោះបុគ្គលដែលត្រូវការ ពារជាអន្តរជាតិ រដ្ឋសមាជិកណាក៏ដោយដែលមានពត៌មាន ពាក់ព័ន្ធនឹងជនរងគ្រោះ និងកាលៈទេសៈពេលប្រព្រឹត្ត ឧក្រិដ្ឋកម្ម ត្រូវប្រឹងប្រែងបញ្ជូនពត៌មាននេះយ៉ាងពេញលេញ និងជាបន្ទាន់ទៅអោយរដ្ឋសមាជិកនោះ ស្របតាម លក្ខណ្ឌផ្សេងៗដែលមានចែងក្នុងច្បាប់ផ្ទៃក្នុង ។

មាត្រា ៦

១. ក្រោយពីយល់ឃើញថា កាលៈទេសៈនោះមានការចាំបាច់ខ្លាំង រដ្ឋសមាជិកដែលជនល្មើសត្រូវចោទប្រកាន់ មានវត្តមានក្នុងទឹកដីរបស់ខ្លួន ត្រូវចាត់វិធានការសមស្របទាំងឡាយ តាមច្បាប់ផ្ទៃក្នុងរបស់ខ្លួនដើម្បី ធានាថាវត្តមានរបស់ជននោះគឺក្នុងគោលបំណងដើម្បីកាត់ទោស ឬធ្វើបត្យាប័ន។ វិធានការទាំងនេះ ត្រូវជូនដំណឹងដោយផ្ទាល់ ឬតាមរយៈលោកអគ្គលេខាធិការអ.ស.ប ដោយគ្មានការពន្យាពេលទៅអោយ :

(ក) រដ្ឋដែលឧក្រិដ្ឋកម្មបានកើតឡើង

(ខ) រដ្ឋ ឬរដ្ឋទាំងឡាយដែលជនល្មើសត្រូវចោទប្រកាន់មានសញ្ជាតិ ឬប្រសិនបើជននោះគ្មានសញ្ជាតិទេ ទឹកដីដែលជននោះមានអាស័យដ្ឋានអចិន្ត្រៃយ៍

(គ) បណ្តារដ្ឋផ្សេងទៀតដែលពាក់ព័ន្ធ និង

(ឃ) អង្គការអន្តរជាតិ ដែលបុគ្គលត្រូវការពារជាអន្តរជាតិ ជាមន្ត្រី ឬជាភ្នាក់ងារ។

២. បុគ្គលណាក៏ដោយ ដែលទទួលរងនូវវិធានការទាំងឡាយក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រានេះត្រូវមានសិទ្ធិ:

(ក) ទំនាក់ទំនងដោយមិនពន្យាពេល ជាមួយតំណាងណាមួយដែលនៅជិតជាងគេ របស់រដ្ឋដែលគាត់ មានសញ្ជាតិ ឬ គាត់មានសិទ្ធិនឹងការពារសិទ្ធិរបស់គាត់ ដែលគាត់បានស្នើ និងមានបំណងការពារសិទ្ធិរបស់ ឬប្រសិន បើគាត់គ្មានសញ្ជាតិរដ្ឋណាមួយទេ និង

(ខ) អោយតំណាងរដ្ឋនោះមកជួប

មាត្រា ៧

រដ្ឋសមាជិកដែលជនល្មើសត្រូវចោទប្រកាន់មានវត្តមាន ប្រសិនបើខ្លួនមិនធ្វើបត្យាប័នជននោះទេ ត្រូវដាក់សំណុំរឿងនេះដោយគ្មានការលើកលែងឬការពន្យាមិនសមហេតុផលពេលណាមួយ ទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន សំរាប់គោលបំណងនៃការកាត់ទោស តាមនីតិវិធីដែលមានចែងក្នុងច្បាប់ផ្ទៃក្នុងរបស់រដ្ឋនោះ។

មាត្រា ៨

១. ក្នុងករណីមួយដែលថា ឧក្រិដ្ឋកម្មទាំងឡាយដែលមានចែងក្នុងមាត្រា២ មិនស្ថិតក្នុងបញ្ជីនៃបទល្មើសដែលត្រូវធ្វើបត្យាប័ន តាមសន្ធិសញ្ញាស្តីពីការធ្វើបត្យាប័ន ដែលមានសុពលភាពរវាងបណ្តារដ្ឋទាំងឡាយទេនោះ ឧក្រិដ្ឋកម្ម ទាំងនោះ ត្រូវបញ្ចូលក្នុងបញ្ជីឈ្មោះឧក្រិដ្ឋកម្មដែលត្រូវធ្វើបត្យាប័ន។ រដ្ឋសមាជិកមានភារកិច្ចបញ្ចូលឧក្រិដ្ឋកម្ម ទាំងនេះ ថាជាបទល្មើសដែលត្រូវធ្វើបត្យាប័ន នៅក្នុងសន្ធិសញ្ញាទាំងឡាយស្តីពីការធ្វើបត្យាប័ននៅពេលអនាគត ដែលនឹងត្រូវធ្វើឡើងរវាងរដ្ឋនិងរដ្ឋទាំងនោះ។

២. ប្រសិនបើរដ្ឋសមាជិកមួយ ដែលកំណត់ការធ្វើបត្យាប័នដោយមានលក្ខខណ្ឌអត្ថិភាពនៃសន្ធិសញ្ញាទទួលបានសំណើពីរដ្ឋសមាជិកមួយផ្សេងទៀត ដែលជាមួយរដ្ឋនេះខ្លួនគ្មានសន្ធិសញ្ញា ស្តីពីការធ្វើបត្យាប័នទេបនោះ ប្រសិនបើសំរេចថាធ្វើបត្យាប័ន ខ្លួនអាចចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនោះ។ ការធ្វើបត្យាប័នត្រូវធ្វើទៅតាមនីតិវិធីនិងលក្ខខណ្ឌផ្សេងៗទៀត នៃច្បាប់របស់រដ្ឋដែលស្នើសុំ។

៣. បណ្តារដ្ឋដែលមិនកំណត់ការធ្វើបត្យាប័នមានលក្ខខណ្ឌ តាមអត្ថិភាពសន្ធិសញ្ញា ត្រូវទទួលស្គាល់ឧក្រិដ្ឋកម្ម ទាំងនោះថាជា បទល្មើសដែលត្រូវធ្វើបត្យាប័ន រវាងរដ្ឋនិងរដ្ឋ អាស្រ័យទៅតាមនីតិវិធី និងលក្ខខណ្ឌផ្សេងៗទៀតនៃ ច្បាប់ផ្ទៃក្នុងរបស់រដ្ឋដែលស្នើ។

៤. សំរាប់គោលបំណងនៃការធ្វើបត្យាប័ន ឧក្រិដ្ឋកម្មនីមួយៗត្រូវពិនិត្យមើល ហាក់ដូចជាវាត្រូវបានកើតឡើង មិនត្រឹមតែក្នុងកន្លែងដែលវាកើតឡើងនោះឡើយ តែថែមទាំងនៅក្នុងទឹកដីនៃបណ្តារដ្ឋ ដែលតំរូវអោយបង្កើតយុត្តាធិការរបស់ខ្លួន ស្របទៅតាមវាក្យខ័ណ្ឌទី១ នៃមាត្រាទី៣។

មាត្រា ៩

បុគ្គលណាក៏ដោយដែលជាកម្មវត្ថុនៃការជំនុំជំរះក្តីកំពុងធ្វើពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងឡាយដែលមានចែងក្នុង មាត្រា២ ត្រូវធានាថាបានទទួលនូវការកាត់ក្តីប្រកបដោយយុត្តិធម៌ នៅគ្រប់ដំណាក់កាលនៃ ការជំនុំជំរះក្តី។

មាត្រា ១០

១. បណ្តារដ្ឋសមាជិកត្រូវផ្តល់អោយទៅគ្នាទៅវិញទៅមក នូវវិធានការជំនួយដ៏ច្រើនបំផុត ពាក់ព័ន្ធនឹងដំណើរ រឿងក្តីព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលមានចែងក្នុងមាត្រា២ ដោយរួមទាំងការផ្តល់នូវភស្តុតាងតាម លទ្ធភាពរបស់ខ្លួន ដែលចាំបាច់ដំណើរការក្តី។

២. បទប្បញ្ញត្តិវាក្យខ័ណ្ឌទី១ នៃមាត្រានេះ មិនត្រូវប៉ះពាល់ដល់កាតព្វកិច្ចពាក់ព័ន្ធនឹង ជំនួយផ្នែកច្បាប់ទៅវិញ ទៅមក ដែលមានចែងក្នុងសន្ធិសញ្ញាផ្សេងទៀត។

មាត្រា ១១

បណ្តារដ្ឋសមាជិកណាដែលនៅទីនោះជនល្មើសដែលត្រូវចោទប្រកាន់ ត្រូវបានកាត់ទោស ត្រូវបញ្ជូនលទ្ធផល ចុងក្រោយនៃដំណើរការក្តីនេះ ទៅលោកអគ្គលេខាធិការអ.ស.ប ដែលនឹងបញ្ជូនពត៌មាននេះទៅបណ្តារដ្ឋសមាជិក ផ្សេងទៀត។

មាត្រា ១២

បទប្បញ្ញត្តិនៃអនុសញ្ញានេះ មិនត្រូវប៉ះពាល់ដល់ការអនុវត្តសន្ធិសញ្ញាទាំងឡាយ ស្តីពីសិទ្ធិជ្រកកោណ ដែលមាន សុពលភាពនៅកាលបរិច្ឆេទនៃការអនុម័តអនុសញ្ញានេះ រវាងបណ្តារដ្ឋដែលជាសមាជិកសន្ធិសញ្ញានោះ។ ប៉ុន្តែ រដ្ឋសមាជិកចំពោះអនុសញ្ញានេះ មិនអាចអនុវត្តសន្ធិសញ្ញាទាំងនោះ ចំពោះរដ្ឋសមាជិកមួយទៀត ចំពោះអនុសញ្ញានេះ ដែលមិនមែនជាភាគីនៃអនុសញ្ញាទាំងនោះ។

មាត្រា ១៣

១. រាល់ជំលោះរវាងរដ្ឋសមាជិកពីរ ឬច្រើន ពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ

ដែលមិន អាចដោះស្រាយបានតាមរយៈការចរចាទេ ត្រូវដាក់ស្នើអោយមានការដោះស្រាយតាមមជ្ឈត្តការ តាមសំណើរបស់ ភាគីមួយ ក្នុងចំណោមភាគីទាំងពីរ។ ប្រសិនបើក្នុងរយៈពេល៦សប្តាហ៍ ចាប់ពីកាលបរិច្ឆេទ នៃការស្នើសុំអោយមាន មជ្ឈត្តករ ភាគីទាំងពីមិនអាចឯកភាពគ្នាក្នុងការបង្កើតមជ្ឈត្តការបានទេនោះ ភាគីណាមួយក៏ដោយអាចដាក់ស្នើ ជំលោះនេះ ទៅតុលាការយុត្តិធម៌អន្តរជាតិ ស្របទៅតាមលក្ខន្តិកៈរបស់តុលាការ។

២. នៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័ន ឬចូលជាសមាជិកចំពោះអនុសញ្ញានេះ រដ្ឋសមាជិកនីមួយៗអាច ប្រកាសថា ខ្លួនមិនមានជាប់កាតព្វកិច្ចតាមបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌទី១ នៃមាត្រានេះ ចំពោះរដ្ឋសមាជិកណាមួយ ដែលបានដាក់ជាលក្ខខណ្ឌដូចគ្នានេះដែរ។

៣. រដ្ឋសមាជិកណាមួយដែលបានដាក់លក្ខខណ្ឌ ស្របទៅតាមវាក្យខ័ណ្ឌទី២នៃមាត្រានេះ អាចប្រកាសដក លក្ខខណ្ឌនេះចេញវិញគ្រប់វេលា តាមរយៈការជូនដំណឹងចំពោះលោកអគ្គលេខាធិការ អ.ស.ប។

មាត្រា ១៤

អនុសញ្ញានេះនឹងបើកចំហរចំពោះហត្ថលេខា របស់បណ្តារដ្ឋទាំងអស់ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៤ នៅឯទីស្នាក់ការអ.ស.ប នៅក្រុងញូវយ៉ក។

មាត្រា ១៥

អនុសញ្ញានេះត្រូវដាក់សុំសច្ចាប័ន។ លិខិតុបករណ៍ផ្តល់សច្ចាប័ន ត្រូវដាក់តំកល់ជាមួយលោកអគ្គលេខាធិការ អ.ស.ប ។

មាត្រា ១៦

អនុសញ្ញានេះត្រូវបើកចំហរសំរាប់ការចូលជាភាគី ពីបណ្តារដ្ឋ។ លិខិតុបករណ៍ចូលជាសមាជិកត្រូវដាក់តំកល់ ជាមួយលោកអគ្គលេខាធិការអ.ស.ប។

មាត្រា ១៧

១. អនុសញ្ញានេះត្រូវចូលជាធរមាន នៅថ្ងៃទី ៣០ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់តំកល់លិខិ

តួបករណ៍ផ្តល់ សច្ចាប័ន ឬលិខិតូបករណ៍ចូលជាសមាជិកទី២២ ជាមួយលោកអគ្គលេខាធិការអ.ស.ប ។

២. ចំពោះរដ្ឋនីមួយៗដែលផ្តល់សច្ចាប័ន ឬចូលជាភាគី នៃអនុសញ្ញានេះ បន្ទាប់ពីការតំកល់លិខិតតូបករណ៍ផ្តល់ សច្ចាប័ន ឬចូលជាសមាជិកលើកទី២២ អនុសញ្ញានេះត្រូវចូលជាធរមានទៅថ្ងៃទី ៣០ បន្ទាប់ពីការដាក់តំកល់លិខិតូប ករណ៍ផ្តល់សច្ចាប័ន ឬចូលជាសមាជិក របស់រដ្ឋទាំងនេះ ។

មាត្រា ១៨

១. រដ្ឋសមាជិកណាក៏ដោយ អាចប្រកាសបដិសេធអនុសញ្ញានេះ ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ ចំពោះលោកអគ្គលេខាធិការអ.ស.ប ។

២. សេចក្តីប្រកាសបដិសេធត្រូវចូលជាធរមាន៦ខែ បន្ទាប់ពីកាលបរិច្ឆេទដែលលោកអគ្គលេខាធិការ អ.ស.ប បានទទួលសេចក្តីជូនដំណឹងនោះ ។

មាត្រា ១៩

អគ្គលេខាធិការអ.ស.បត្រូវជូនពត៌មានដល់បណ្តារដ្ឋ ដូចជា:

(ក) ពីហត្ថលេខាចំពោះអនុសញ្ញានេះ ការតំកល់លិខិតូបករណ៍ផ្តល់សច្ចាប័ន ឬចូលជាសមាជិក ស្របតាម មាត្រា ១៤ ១៥ និង១៦ និងសេចក្តីជូនដំណឹង តាមមាត្រា១៨

(ខ) ពីកាលបរិច្ឆេទដែលអនុសញ្ញានេះនឹងចូលជាធរមាន ស្របតាមមាត្រា១៧ ។

មាត្រា ២០

អត្ថបទដើមនៃអនុសញ្ញានេះ ដែលអត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានសុពលភាពស្មើគ្នា ត្រូវតំកល់ទុកនៅជាមួយលោកអគ្គលេខាធិការអ.ស.ប ដែលលោកនឹងផ្ញើអត្ថបទដោយមានការបញ្ជាក់ផង ទៅបណ្តារដ្ឋទាំងឡាយ ។

ដើម្បីជាសាក្សីចំពោះអនុសញ្ញានេះ អ្នកដែលចុះហត្ថលេខាខាងក្រោម ដែលទទួលបានការអនុញ្ញាតស្របច្បាប់ ដោយរដ្ឋាភិបាលខ្លួន បានចុះហតលេខាលើអនុសញានេះ ដែលបានបើកចំហរសំរាប់ហត្ថលេខា នៅក្រុងញូវយ៉ក នាថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៣ ។

៣១៦១ (XXVIII) ការបញ្ចូលភាសាចិនទៅក្នុងចំណោមភាសាទាំងឡាយដែលប្រើប្រាស់ សំរាប់

មហាសន្និបាត គណៈកម្មាធិការរបស់ខ្លួន និង ការបញ្ចូលភាសាអារ៉ាប់ ក្នុងចំណោមភាសា សំរាប់ការងារ និងផ្លូវការ របស់មហាសន្និបាត និងគណៈកម្មាធិការសំខាន់ៗរបស់ខ្លួនៈ វិសោធនកម្មទៅលើវិធាន ៥១-៥៩ នៃវិធានទីតិវិធីរបស់មហាសន្និបាត

មហាសន្និបាត

យោងសេចក្តីសំរេចចិត្តរបស់ខ្លួន
ដើម្បីបញ្ចូលភាសាចិនទៅក្នុងភាសាសំរាប់បំពេញការងាររបស់មហាសន្និបាត និងដើម្បីធ្វើវិសោធនកម្មបទបញ្ញត្តិពាក់ព័ន្ធ នៃវិធានទីតិវិធីរបស់មហាសន្និបាត[៣៥]

យោងសេចក្តីសំរេចចិត្តរបស់ខ្លួនដើម្បីបញ្ចូលភាសាអារ៉ាប់ ទៅក្នុងចំណោមភាសាសំរាប់បំពេញការងារ និង ផ្លូវការ របស់មហាសន្និបាតនិងគណៈកម្មាធិការសំខាន់ៗរបស់ខ្លួន និងដើម្បីធ្វើវិសោធនកម្មបទបញ្ញត្តិពាក់ព័ន្ធ នៃវិធានទីតិវិធីរបស់មហាសន្និបាត[៣៦]

ដោយបានពិចារណាពីកំណត់សំគាល់របស់លោកអគ្គលេខាធិការអ.ស.ប

សំរេច ដែលមានប្រសិទ្ធភាពពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧៤ :

(ក) ដាក់ជំនួសវិធាន៥១-៥៩ នៃវិធានទីតិវិធីរបស់មហាសន្និបាត ដោយវិធានដូចខាងក្រោមៈ

" VIII ភាសា"

" ភាសាផ្លូវការ និងសំរាប់ធ្វើការងារ"

" វិធាន ៥១"

" ភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្ប៉ាញ ត្រូវតែជាភាសាទាំងផ្លូវការនិងភាសាការងាររបស់មហាសន្និបាត គណៈកម្មាធិការ និងអនុគណៈកម្មាធិការរបស់ខ្លួន។ ភាសាអារ៉ាប់ត្រូវតែជាភាសាទាំងភាសាការងារ និងផ្លូវការ របស់ មហាសន្និបាត និងគណៈកម្មាធិការសំខាន់ៗរបស់ខ្លួន"។

" ការបកប្រែ"

" វិធាន ៥២"

សុន្ទរកថាដែលនឹងត្រូវធ្វើឡើងដោយភាសាណាមួយ ក្នុងចំណោមភាសាទាំង៦ ត្រូវបកប្រែជាភាសាទាំង៥ ផ្សេងទៀត ល្គឹកណាតែការបកប្រែមកពី និងទៅជាភាសាអារ៉ាប់ ត្រូវធ្វើឡើងតែនៅក្នុងមហាសន្និបាត និងគណៈកម្មាធិការសំខាន់ៗរបស់ខ្លួន។

" វិធាន ៩៣ "

តំណាងណាក៏ដោយអាចថ្លែងសុន្ទរកថាជាភាសាមួយ ក្រៅពីភាសាទាំងឡាយរបស់មហាសន្និបាត។ ក្នុង ករណីនេះខ្លួនគាត់ផ្ទាល់ត្រូវធ្វើការបកប្រែ ទៅជាភាសាណាមួយរបស់មហាសន្និបាត ឬគណៈកម្មាធិការ ដែលពាក់ព័ន្ធ។ ការបកប្រែជាភាសាណាមួយរបស់មហាសន្និបាត ឬគណៈកម្មាធិការពាក់ព័ន្ធ ដោយអ្នកបក ប្រែរបស់លេខាធិការដ្ឋាន អាចនឹងផ្អែកលើការបកប្រែ ដែលបានធ្វើឡើងជាភាសាបែបនេះលើកទី១។

" ភាសានៃការចំលងតាមច្បាប់ដើម និងរបាយការសង្ខេប "

" វិធាន ៩៤ "

" ការចំលងតាមច្បាប់ដើម ឬរបាយការណ៍សង្ខេប ត្រូវរៀបចំអោយបានឆាប់ តាមភាសាទាំងឡាយ របស់មហា សន្និបាត ល្គីកណាតែរបាយការណ៍ទាំងនេះត្រូវរៀបចំជាភាសាអារ៉ាប់ សំរាប់កិច្ចប្រជុំពេញអង្គ របស់មហាសន្និបាត និងសំរាប់កិច្ចប្រជុំរបស់គណៈកម្មាធិការសំខាន់ៗ។

" ភាសាសំរាប់ទស្សនាវដ្ដី របស់អ.ស.ប "

" វិធាន ៩៥ "

" ក្នុងកំឡុងពេលនៃកិច្ចប្រជុំរបស់មហាសន្និបាត ទស្សនាវដ្ដីរបស់អ.ស.ប ត្រូវបោះពុម្ពផ្សាយជា ភាសាទាំង ឡាយ របស់មហាសន្និបាត " ។

" ភាសាសំរាប់សេចក្ដីសំរេចចិត្ត និងឯកសារផ្សេងទៀត "

" វិធាន ៩៦ "

" រាល់សេចក្ដីសំរេចចិត្តនិងឯកសារផ្សេងៗទៀត ត្រូវបោះពុម្ពផ្សាយជាភាសារបស់មហាសន្និបាត ល្គីកណាតែ កាបោះពុម្ពផ្សាយជាភាសាអារ៉ាប់ ចំពោះឯកសារទាំងនោះ ត្រូវកំណត់ចំពោះឯកសារទាំងឡាយ របស់មហាសន្និបាត និងគណៈកម្មាធិការសំខាន់ៗរបស់ខ្លួន។

" ការបោះពុម្ពផ្សាយជាភាសាទាំងឡាយ ក្រៅពីភាសាទាំងឡាយរបស់មហាសន្និបាត "

" វិធាន ៩៧ "

ឯកសារទាំងឡាយរបស់មហាសន្និបាត គណៈកម្មាធិការ និងអនុគណៈកម្មាធិការរបស់ខ្លួន ប្រសិនបើមហាសន្និបាតសំរេចថាបោះផ្សាយនោះត្រូវបោះពុម្ពផ្សាយចាភាសណាមួយក្រៅពីភាសាទាំងឡាយ របស់មហាសន្និបាត ឬគណៈកម្មាធិការពាក់ព័ន្ធ ។

(ខ) ចុះលេខនូវវិធានទាំងឡាយជាបន្តបន្ទាប់។

កិច្ចប្រជុំលើកទី ២២០៦

ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៧៣

89 United Nations, Treaty Series, vol. 330, No. 4739, p. 38
32 Sec " Other decision ", p. 150
32 Official record of the General Assembly, Twenty-seventh Session, Supplement No. 10 (A/8710/Rev.1), Chap. 111, Sect. B
33 A/9127 and Add.1.
33 See resolution 3189 (XXVIII)
36 See resolution 3190 (XXVIII)